ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សារលិខិតជូនពរ

សូមគោរពជូន

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់!

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានបីតិសោមនស្សរីករាយ និងសូមអបអរសាទរយ៉ាងកក់ក្តៅ ក្នុងឱកាសដែលព្រះករុណាព្រះបាទបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **សម្តេចក្រឡាហោម** ជូនចំពោះសម្តេចឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពដោយស្មោះចំពោះ **សម្តេច** ដែលបានយកអស់កម្លាំងកាយចិត្តចូលរួមដឹកនាំ កសាងនូវសន្តិភាពជាតិ ឯកភាពជាតិ ស្ថិរភាពសន្តិសុខសង្គម និងការអភិវឌ្ឍលើគ្រប់វិស័យ ព្រមទាំងរក្សាការពារបូរណភាពទឹកដីជូនប្រជាជាតិទាំងមូល និងមាតុភូមិកម្ពុជា។

ជាថ្មីម្តងទៀតយើងខ្ញុំ សូមបួងសួងដល់ទេវតាឆ្នាំថ្មី ឆ្នាំមមែ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកនាំមកនូវសិរីសួស្តី ជ័យមង្គល វិបុលសុខជូនចំពោះ **សម្តេចក្រឡាហោម និងលោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវគោរពភក្តីដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ប្រាក់ សុខុន
រដ្ឋមន្ត្រី និងជាតំណាងមន្ត្រីរាជការ
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍